ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការផលិតសម្ភារៈពិសោធ

# និងវិធីសាស្ត្របង្រៀនពិសោធ

## មុខវិជ្ជា គីមីវិទ្យា

ប្រើប្រាស់ថវិការបស់គម្រោងអភិវឌ្ឍន៍

វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ( USESDP )

---

រាជធានីភ្នំពេញ ឆ្នាំ២០២១

# បុព្វកថា

ទស្សនវិស័យនៃការអប់រំសតវត្សរ៍ទី២១ បានកំណត់យកការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឌីជីថល ជាមូលដ្ឋានគន្លឹះក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០៣០ និង២០៥០ ដូចមានចែងក្នុងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម។ ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំឆ្នាំ២០១៨-២០២៣ ដោយផ្តោតលើការកែលម្អវិធីសាស្ត្របង្រៀន និងរៀន ការផលិតសម្ភារឧបទេស សម្ភារៈពិសោធ ការពិសោធ និងសម្ភារៈបណ្ណាល័យ ដើម្បីឆ្ពោះទៅរកគុណភាពអប់រំប្រកបដោយចីរភាពនៅមធ្យមសិក្សាទុតិយភូមិទូទាំងប្រទេសកម្ពុជា។ ការធ្វើពិសោធលើមុខវិជ្ជាវិទ្យាសាស្ត្រ ពិតជាមានអត្ថប្រយោជន៍យ៉ាងច្រើន ចំពោះការបង្រៀន និងរៀន ដែលជួយឱ្យសិស្សចេះអភិវឌ្ឍខ្លួនឯង មានជំនាញកំណត់ទិសដៅ ចេះរៀបចំផែនការ និងដោះស្រាយបញ្ហា ជំរុញការអភិវឌ្ឍគំនិតបញ្ញា មានជំនឿទុកចិត្តលើចំណេះដែលទទួលបានពីការពិសោធ បង្កើតនូវគំនិតច្នៃប្រឌិតថ្មី បណ្តុះបំណិនវិជ្ជាជីវៈ ចេះអំពីរបៀបសួរសំណួរ គិតស៊ីជម្រៅ ស្រាវជ្រាវ សង្កេត វិភាគ និងយល់ដឹងអំពីពិភពលោកកាន់តែប្រសើរ។

វិទ្យាស្ថានជាតិអប់រំ បានរៀបចំចងក្រងសៀវភៅពិសោធ សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិផ្នែកវិទ្យាសាស្ត្រ ដែលខ្លឹមសារសៀវភៅរួមមាន ការរៀបចំសន្និកកិច្ចការពិសោធ សម្ភារៈពិសោធ វិធីសាស្ត្របង្រៀនពិសោធ និងការធ្វើពិសោធជាក់ស្តែង។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមទុកថា ឯកសារនេះ នឹងបានជាប្រយោជន៍ដ៏សំខាន់ សម្រាប់អ្នកអនុវត្ត ជាពិសេសគ្រូបង្រៀននៅសាលាមធ្យមសិក្សាទុតិយភូមិដែលទទួលបានការបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំ ក្នុងការអនុវត្តពិសោធ ប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ និងជំរុញការអប់រំវិទ្យាសាស្ត្រនៅកម្ពុជាឱ្យមានការអភិវឌ្ឍដូចបណ្តាប្រទេសនានាក្នុងតំបន់ និងលើសកលលោក។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# អារម្ភកថា

ការអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឱ្យមានគុណភាពទាំងផ្នែក ចំណេះដឹង បំណិន និងឥរិយាបថ។

ឯកសារបំប៉នផ្នែកពិសោធន៍គីមីវិទ្យា ត្រូវបានរៀបចំឡើងដើម្បីប្រើប្រាស់ក្នុងគោលបំណងលើកកម្ពស់ សមត្ថភាព ឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង្ហាត់បង្រៀនសិស្សស្របតាមកម្មវិធីសិក្សា និងសៀវភៅនៅ សាលាចំណេះទូទៅបច្ចុប្បន្ន ជាពិសេសក្នុងកម្រិតវិទ្យាល័យ។

ខ្លឹមសារនៅក្នុងសៀវភៅនេះចែកចេញជាបីផ្នែករួមមាន៖ ១. ការផលិតសម្ភារឧបទេសគឺសំដៅលើការ ច្នៃ សម្ភារឧបទេសងាយៗ របៀបប្រើប្រាស់សម្ភារៈពិសោធ។ ២. ការសរសេរសន្លឹកកិច្ចការពិសោធគឺសំដៅ លើការអនុវត្តវិធីសាស្ត្របង្រៀនមានដូចជា បង្រៀន និងរៀនបែបរិះរក ការប្រើវិធីវិទ្យាសាស្ត្រជាដើម។ ៣. សារប្រយោជន៍នៃ សម្ភារឧបទេស ជាចំណែកមួយក្នុងការពង្រីកចំណេះដឹងរបស់គ្រូ ដែលធ្វើឱ្យការបង្រៀន និងរៀនកាន់តែមាន ប្រសិទ្ធភាពថែមទៀត។

យើងសង្ឃឹមថាសៀវភៅនេះនឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់គ្រូបង្រៀនផ្នែកគីមីវិទ្យា សម្រាប់ជួយសម្រួលដល់គ្រូបង្រៀនក្នុងការបង្រៀនពិសោធដោយប្រើប្រាស់សន្លឹកកិច្ចការពិសោធ។ វាជា ការជម្រុញនិងលើក ទឹកចិត្តក្នុងការបង្រៀន និងរៀនដោយប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល ដើម្បីឱ្យ ការបង្រៀន និងរៀន ប្រកបដោយគុណភាព។

យើងខ្ញុំជឿជាក់ថាឯកសារនេះចំណុចខ្វះចន្លោះដោយជៀសមិនផុតឡើយ។ ខ្ញុំសង្ឃឹមថាលោកគ្រូអ្នក គ្រូ និងជួយផ្តល់យោបល់បំពេញបន្ថែម ក្នុងន័យស្ថាបនាដើម្បីកែលម្អឯកសារនេះឱ្យកាន់តែមានលក្ខណៈល្អ ប្រសើរថែមទៀត។

**គណៈកម្មការនិពន្ធ**

## **១.គណៈកម្មការគ្រប់គ្រង**

១.ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២.ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

៣.ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ

៤.លោក **ថៃ ហេង** នាយករងវិទ្យាស្ថានជាតិអប់រំ

## **២.គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រងសៀវភៅ**

១- លោក **មាស ចាន់** គ្រូឧទ្ទេសគីមីវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

២- លោក **ប៉ែន សំភា** គ្រូឧទ្ទេសគីមីវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

៣- លោកស្រី **លន់ តូនី** គ្រូឧទ្ទេសគីមីវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

៤- លោកស្រី **ម៊ួរ បូលីនដា** គ្រូឧទ្ទេសគីមីវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

## **៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ**

១-លោក **ម៉ៅ សារឿន** ប្រធានដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

២-លោក **ចេង ថុន** អនុប្រធានដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

៣-លោក **គឹម លាង** អនុប្រធានដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

# មាតិកា


បុព្វកថា ..... I

អារម្ភកថា ..... II

មាតិកា ..... IV

១. សេចក្តីផ្តើម ..... 1

២. គោលបំណង ..... 1

៣ .និយមន័យ ..... 1

៤. ប្រភព ..... 2

៥. ឈ្មោះសារធាតុគីមី និងសម្ភារឧបទេសមួយចំនួន ..... 2

៥.១.តារាងបញ្ជីឈ្មោះសារធាតុគីមី ..... 2

៥.២.ការប្រើប្រាស់សម្ភារៈ ..... 5

៦. ការសរសេរសន្លឹកកិច្ចការពិសោធន៍ ..... 11

៦.១.ប្រធានបទទី១ "ការកំណត់កំហាប់ភាគរយអាស៊ីតអេតាណូអ៊ិចក្នុងទឹកខ្មេះ" ..... 11

៦.២.ប្រធានបទទី២ កត្តាជះឥទ្ធិពលលើល្បឿនប្រតិកម្ម ..... 13

៧.វិធីសាស្ត្របង្រៀន និងរៀនពិសោធន៍ ..... 16

៨.សារប្រយោជន៍នៃសម្ភារៈឧបទេស ..... 16

៩. ឯកសារយោង ..... 18

## ១. សេចក្តីផ្តើម

ការបង្រៀនជាមាគ៌ាក្នុងការផ្តល់ចំណេះដឹងដល់សិស្សតាមរយៈការប្រើប្រាស់វិធីសាស្ត្រ យុទ្ធវិធីឱ្យសិស្សមានការអភិវឌ្ឍន៍ផ្នែកបញ្ញាស្មារតី និងរាងកាយ ។

វិធីបង្រៀនគឺជាល្បិច ឬជាមធ្យោបាយធ្វើឱ្យការងាររបស់គ្រូបង្រៀន និងសិស្សក្រោមការដឹកនាំរបស់គ្រូ សិស្សទទួលបាននូវចំណេះដឹង ចំណេះធ្វើ បំណិនប្រសប់ ចេះរស់នៅជាមួយគ្នាព្រមទាំងពង្រីកសតិបញ្ញាស្មារតីរបស់សិស្ស សំដៅលើការប្រតិបត្តិនូវការគ្រប់គ្រងភារកិច្ចនៃការបង្រៀន។

គោលវិធីនៃការបង្រៀនត្រូវបានស្គាល់ជាទូទៅថាមានពីរធំៗគឺ គោលវិធីគ្រូមជ្ឈមណ្ឌល និងគោលវិធីសិស្សមជ្ឈមណ្ឌល។

គោលវិធីសិស្សមជ្ឈមណ្ឌលមាន វិធីពិភាក្សា វិធីរៀនតាមបែបរិះរក វិធីវិទ្យាសាស្ត្រ...។

## ២. គោលបំណង

- បង្ហាញពីរបៀបសរសេរសន្លឹកកិច្ចការពិសោធន៍
- កំណត់បានពីប្រភពនៃសម្ភារឧបទេស
- រៀបរាប់បានពីរបៀបប្រើប្រាស់សម្ភារៈពិសោធន៍
- កែច្នៃសម្ភារឧបទេសងាយៗដើម្បីជាជំនួយក្នុងការបង្រៀនពិសោធន៍
- ជ្រើសរើសវិធីសាស្ត្រក្នុងការបង្រៀនពិសោធន៍
- រៀបរាប់បានពីសារប្រយោជន៍នៃការប្រើប្រាស់សម្ភារឧបទេសក្នុងការរៀន និងបង្រៀន
- ជំរុញនិងលើកទឹកចិត្តគ្រូបង្រៀនឱ្យបង្រៀនដោយប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល

## ៣ .និយមន័យ

- សម្ភារឧបទេស ជាឧបករណ៍ ឬសម្ភារជាក់ស្តែងដែលគ្រូត្រូវប្រើប្រាស់សម្រាប់បង្រៀននិងរៀនដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែច្បាស់លាស់ ហើយងាយយល់។
- វាអាចជាសម្ភារៈងាយរកបាន សម្ភារៈច្នៃប្រឌិតដូចជា សៀវភៅសិស្ស សៀវភៅគ្រូ រូបភាព រូបថតប័ណ្ណ សំណួរ ឧបករណ៍ពិសោធន៍ សន្លឹកកិច្ចការ...សម្ភារៈចាំបាច់ដទៃទៀតសមស្របតាមមេរៀន។
- វិធីសាស្ត្រតាមបែបរិះរក តម្រូវឱ្យសិស្សសង្កេត និងវិភាគអំពីបាតុភូតវិទ្យាសាស្ត្រ ដើម្បីបង្កើតសំណួរធ្វើពិសោធ ឬធ្វើការស្រាវជ្រាវដើម្បីឆ្លើយទៅនឹងសំណួររបស់ពួកគេ និងទាញសេចក្តីសន្និដ្ឋានសមស្របមួយ តាមរយៈលទ្ធផលការធ្វើពិសោធន៍ ឬការសិក្សាស្រាវជ្រាវ។ នៅក្នុងដំណើរការនេះ សិស្សនឹងយល់ពីខ្លឹមសារ បានស៊ីជម្រៅ ទទួលបានជំនាញ និងចំណេះដឹងបែបវិទ្យាសាស្ត្រយ៉ាងពិតប្រាកដ។
- វិធីវិទ្យាសាស្ត្រៈ វិទ្យាសាស្ត្រជាការសិក្សាស្វែងយល់អំពីបាតុភូត ហេតុការណ៍ ឬព្រឹត្តិការណ៍ផ្សេងៗដែលកើតមានឡើងជុំវិញខ្លួនយើង ថាហេតុអ្វី បានជាមានបាតុភូតនោះកើតឡើង ហើយព្យាយាមពន្យល់អំពីបាតុភូតនោះដើម្បីឱ្យគេបានដឹង បានយល់។ អ្នកដែលព្យាយាមពន្យល់ឱ្យគេបានយល់ពី

បាតុភូត ឬហេតុការណ៍ទាំងនោះត្រូវបានគេហៅថា "អ្នកវិទ្យាសាស្ត្រឬ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រ" ។ ក្នុងការស្រាវជ្រាវ អ្នកវិទ្យាសាស្ត្របានប្រើវិធីរួមមួយ ហៅថា វិធីវិទ្យាសាស្ត្រ។

## ៤. ប្រភព

សម្ភារឧបទេស ជាតំរូវការចាំបាច់មួយសម្រាប់ការបង្រៀនប្រកបដោយប្រសិទ្ធភាព។

ប្រភពនៃសម្ភារឧបទេស:

- អាចរកបាននៅក្នុងបណ្ណាល័យ(ឯកសារពាក់ព័ន្ធ)
- មាននៅក្នុងមន្ទីរពិសោធ(ចំពោះវិទ្យាសាស្ត្រ)
- អាចច្នៃប្រឌិតបានដោយងាយ និងមានតម្លៃសមស្រប
- ទាក់ទងទៅនឹងសម្ភារៈប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ
- ទីផ្សារលក់គ្រឿងជ័រ លក់គ្រឿងអគ្គិសនី លក់ល័ក្ក លក់ឱសថ ជាដើម

## ៥. ឈ្មោះសារធាតុគីមី និងសម្ភារឧបទេសមួយចំនួន

### ៥.១.តារាងបញ្ជីឈ្មោះសារធាតុគីមី

| លរ. | រាយមុខសម្ភារៈ | សភាពនៃសារធាតុ |
|---|---|---|
| 1 | 1-buffer solution pH 4.01<br>2-buffer solution pH 7.00<br>3-buffer solution pH 9.00 | ជាអង្គធាតុរាវ ដាក់ដបចំណុះ 500ml<br>ជាអង្គធាតុរាវ ដាក់ដបចំណុះ 500ml<br>ជាអង្គធាតុរាវ ដាក់ដបចំណុះ 500ml |
| 2 | Acetone carmine | ជាអង្គធាតុរាវ ដាក់ដបចំណុះ 100ml |
| 3 | Petroleum Ether 40-60 | ជាអង្គធាតុរាវ ដាក់ដបចំណុះ 500ml |
| 4 | Bromothymol blue | ជាអង្គធាតុរាវ ដាក់ដបចំណុះ 50ml<br>ឬជាក្រាមរឹង ដាក់ដប បរិមាណ 25 g |
| 5 | Methyl blue (Aniline blue) | ជាអង្គធាតុរាវ ដាក់ដបចំណុះ 50ml<br>ឬជាក្រាមរឹង ដាក់ដប បរិមាណ 25 g |
| 6 | Indigo carmine | ជាក្រាមរឹង ដាក់ដប បរិមាណ 25 g |
| 7 | Amylase, from Aspergillus oryzae | ជាម្សៅ ដាក់ដប បរិមាណ 100 g |
| 8 | Acetone | ជាអង្គធាតុរាវ ដាក់ដបចំណុះ 50ml |
| 9 | Aluminum Oxide | ជាម្សៅ ដាក់ដប បរិមាណ 500 g |
| 10 | Silver nitrate | ជាក្រាមរឹង ដាក់ដប បរិមាណ 100 g |
| 11 | RM027 yeast Extract | ជាម្សៅ ដាក់ដប បរិមាណ 500g |
| 12 | Sodium carbonate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 13 | Trichloroacetic acid | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 14 | Ethanoic acid (Acetic acid) | ជាអង្គធាតុរាវ ដាក់ដបចំណុះ:500ml |
| 15 | Methanoic acid (Formic acid) | ជាអង្គធាតុរាវ ដាក់ដបចំណុះ:500ml |

| | | |
|---|---|---|
| 16 | Bromine 99% | ជាអង្គធាតុរាវ ដាក់ដបចំណុះ500ml |
| 17 | Calcium carbonate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 18 | Hydrogen peroxide 30% | ជាអង្គធាតុរាវ ដាក់ដបចំណុះ500ml |
| 19 | Cobalt ( II ) chloride | ជាក្រាមរឹង ដាក់ដប បរិមាណ100g |
| 20 | Copper ( II ) chloride.$2H_2O$ | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 21 | Iron ( II ) chloride .$4H_2O$ | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 22 | Iron ( II ) chloride | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 23 | Citric acid .$H_2O$ | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 24 | Methanol AR | ជាអង្គធាតុរាវ ដាក់ដបចំណុះ500ml |
| 25 | Aluminum foil | ជាក្រាមរឹង ដាក់ដប បរិមាណ250g |
| 26 | Sulfuric acid | ជាអង្គធាតុរាវ ដាក់ដបចំណុះ500ml |
| 27 | Nitric acid | ជាអង្គធាតុរាវ ដាក់ដបចំណុះ500ml |
| 28 | Hydrochloric acid | ជាអង្គធាតុរាវ ដាក់ដបចំណុះ500ml |
| 29 | Aluminum sulfate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 30 | Ammonium hydroxide | ជាអង្គធាតុរាវ ដាក់ដបចំណុះ500ml |
| 31 | Ammonium nitrate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 32 | Potassium chlorate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 33 | Ammonium sulfate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 34 | Barium hydroxide | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 35 | Anhydrate calcium chloride | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 36 | Calcium sulfate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 37 | Active carbon | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 38 | Chloroform ,500ml | ជាអង្គធាតុរាវ ដាក់ដបចំណុះ500ml |
| 39 | Copper sulfate $CuSO_4$ | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 40 | Copper foil | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 41 | Iron filing | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 42 | Iron( III )oxide | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 43 | Iron ( II ) oxide | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 44 | Fructose D | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 45 | Silica gel w/indicator blue | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 46 | Diethyl ether | ជាអង្គធាតុរាវ ដាក់ដប បរិមាណ500ml |
| 47 | Glycerol | ជាក្រាមរឹង ដាក់ដប បរិមាណ500g |

| | | |
|---|---|---|
| 48 | Methyl orange | ជាក្រាមរឹង ដាក់ដប បរិមាណ25g |
| 49 | Hydroquinone | ជាក្រាមរឹង ដាក់ដប បរិមាណ250g China Btl |
| 50 | Magnesium ribbon | ជាក្រាមរឹង ដាក់ដប បរិមាណ25g China Btl |
| 51 | Magnesium chloride $MgCl_2$ | ជាក្រាមរឹង ដាក់ដប បរិមាណ500g China Btl |
| 52 | Manganese Oxide $MnO_2$ | ជាក្រាមរឹង ដាក់ដប បរិមាណ500g India Btl |
| 53 | Manganese Oxide $MnO_2$ | ជាក្រាមរឹង ដាក់ដប បរិមាណ500g India Btl |
| 54 | Methanal -formaldehyde | 500ml China Btl |
| 55 | Phenol | ជាក្រាមរឹង ដាក់ដប បរិមាណ500g China Btl |
| 56 | Phenolphthalein | ជាក្រាមរឹង ដាក់ដប បរិមាណ25g China Btl |
| 57 | Phenolphthalein color red,250ml | ជាអង្គធាតុរាវ ដាក់ដបចំណុះ 50ml<br>ឬជាក្រាមរឹង ដាក់ដប បរិមាណ 25 g |
| 58 | Lead | ជាបន្ទះស្តើងៗ ទំហំប្រហែល 10cm x 15cm |
| 59 | Lead acetate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 60 | Lead nitrate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 61 | Lead sulfate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 62 | Potassium bromide | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 63 | Potassium carbonate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 64 | Potassium chlorate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 65 | Potassium chloride | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 66 | Potassium dichromate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 67 | Potassium ferrocyanide$K_4FeCN_6$ | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 68 | Potassium Iodide | ជាក្រាមរឹង ដាក់ដប បរិមាណ 500g |
| 69 | Potassium nitrate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |
| 70 | Potassium Permanganate | ជាក្រាមរឹង ដាក់ដប បរិមាណ500g |

## ៥.២.ការប្រើប្រាស់សម្ភារៈ

### កែវបេស៊ែ

ប្រភេទៈ កែវបេស៊ែ អាចជាកែវឬជាជ័រថ្លាដែលមានទំហំផ្សេងៗគ្នាដូចជា 10mL, 25mL, 50mL, 100mL, 250mL, 500mL, 1000mL..... ។កែវបេស៊ែដែលផលិតចេញពីកែវមានពីរប្រភេទទៀតគឺកែវ PYREX និងមិនមែនជា PYREX។ យើងអាចដឹងពីប្រភេទកែវទាំងនេះដោយពិនិត្យមើលអក្សរដែលគេសរសេរលើសំបកកែវស្រាប់។



កែវប្រភេទ PYREX ដែលមានលក្ខណៈធន់នឹងកម្តៅជាងកែវមិនមែនជាប្រភេទ PYREXតែជាអាចប្រើវាបានដូចគ្នា ។

**របៀបប្រើប្រាស់:** ដុតកម្តៅអង្គធាតុរាវផ្សេងៗឱ្យពុះ។ ផ្ទុកសារធាតុគីមីផ្សេងៗក្នុងរយៈពេលខ្លី។ រំលាយ និង ធ្វើសូលុយស្យុងផ្សេងៗ។ ផ្ទេរសូលុយស្យុងឬសារធាតុគីមី។

### កែវអ៊ែកឡែន

ប្រភេទៈ កែវអ៊ែកឡែន អាចជាកែវឬជាជ័រថ្លាដែលមានទំហំផ្សេងៗគ្នាដូចជា 10mL, 25mL, 50mL, 100mL, 250mL, 500mL, 1000mL។......




កែវអ៊ែកឡែនដែលផលិតចេញពីកែវមានពីរប្រភេទទៀតគឺ កែវ PYREX និងមិនមែនជា PYREX។ យើងអាចដឹងពីប្រភេទ កែវទាំងនេះដោយពិនិត្យមើលអក្សរដែលគេសរសេរលើ សំបកកែវស្រាប់។ កែវប្រភេទ PYREX មានលក្ខណៈធន់ នឹងកម្តៅជាងកែវមិនមែនជាប្រភេទ PYREX តែអាច ប្រើវាបានដូចគ្នា។

របៀបប្រើប្រាស់: ដូចគ្នានឹងកែវបេស៊ែដែរតែ កែវអ៊ែកឡែន គេអាចប្រើវាសម្រាប់ស្តុកទុកសូលុយស្យុងបាន ព្រោះវាមានមាត់តូចបិតដោយឆ្នុកបាន។ មួយវិញ ទៀត កែវអ៊ែកឡែនគេនិយមប្រើសម្រាប់ដាក់សូលុយស្យុងដែលត្រូវធ្វើអត្រាកម្មក្នុងពិសោធន៍អត្រាកម្ម ក៏ព្រោះវាជួយការពារពីការខ្ទាត ឬកំពប់សូលុយស្យុងបានប្រសើរជាងកែវបេស៊ែ។

### បំពង់សាក

ប្រភេទៈ បំពង់សាកអាចមានទំហំតូចធំ និងមានប្រភេទ PYREX និងមិនមែន PYREX ដែលគេអាចមើលឃើញនៅលើបំពង់សាក។ បំពង់សាកខ្លះមានក្រិតមាឌនៅលើនោះ តែបំពង់សាកភាគច្រើនពុំមានក្រិតទេ។

របៀបប្រើប្រាស់: បំពង់សាកអាចត្រូវបានប្រើសម្រាប់ដុតកម្ដៅអង្គធាតុរឹងផ្សេងៗដោយផ្ទាល់ អណ្ដាតភ្លើងក្នុងប្រតិកម្មបំបែកដោយកម្ដៅ។ ដុតកម្ដៅអង្គធាតុរាវ។ តេស្តមើលពីប្រតិកម្មផ្សេងៗ ដូចជាការប្ដូរពណ៌ ការបង្កើតកករ និងការបង្កើតឧស្ម័នជាដើម។ ត្រងយកឧស្ម័នដែល ភាយចេញពីប្រតិកម្មផ្សេងៗដូចជាក្នុងអគ្គិសនីវិភាគ។



**ទែម៉ូម៉ែត្រ**

ប្រភេទ: ទែម៉ូម៉ែត្រមានពីរប្រភេទ គឺប្រភេទអាណាឡូក និងប្រភេទឌីជីថល។ ទែម៉ូម៉ែត្រដែលគេប្រើញឹកញាប់ក្នុងមន្ទីរពិសោធគឺប្រភេទអាណាឡូក ដែលប្រភេទនេះអាចជាទែម៉ូម៉ែត្របារ៉ាតពណ៌សដូចប្រាក់និងទែម៉ូម៉ែត្រអាល់កុលពណ៌ក្រហមឬខៀវ។ ទែម៉ូម៉ែត្រឌីជីថលជាទូទៅគេប្រើអគ្គិសនី និងមានអេឡិចត្រូចលោហៈដែលគេអាចវាស់សីតុណ្ហភាពដោយសារអេឡិចត្រូតលោហៈនេះនិងអាចអានតម្លៃសីតុណ្ហភាពនៅលើអេក្រង់បាន។



របៀបប្រើប្រាស់: គេអាចប្រើទែម៉ូម៉ែត្រវាស់សីតុណ្ហភាពផ្សេងៗ ដូចជាសីតុណ្ហភាពរលាយសីតុណ្ហភាពរំពុះនៃសារធាតុគីមីជាដើមដោយដាក់វាចូលទៅក្នុងតំបន់ដែលចង់វាស់សីតុណ្ហភាពនិងអានតម្លៃ តាមរយៈក្រិតឬអេក្រង់ដែលបានបង្ហាញ។

**ស៊ីឡាំងក្រិត**

ប្រភេទ: ស៊ីឡាំងក្រិតមានជាប្រភេទកែវ និងប្រភេទជ័រ។

វាអាចមានទំហំតូច ធំដូចជាចំណុះ 10ml, 50ml, 100ml, 500ml, 1000ml" របៀបប្រើប្រាស់: មុខងារ

សំខាន់នៃការប្រើប្រាស់ស៊ីឡាំងក្រឹតគឺដើម្បីវាស់មាឌរបស់វត្ថុនានាអាចជាអង្គធាតុរាវ រឹង និងឧស្ម័ន។ ក្រៅពីនោះគេក៏អាចប្រើស៊ីឡាំងក្រិតសម្រាប់ពង្រាវសូលុយស្យុង ជំនួសកែវវាស់មាឌផងដែរ។



## ដបលាង

ប្រភេទ៖  ជាប្រភេទដបជ័រដែលមានទុយោរឹងភ្ជាប់ទៅនឹងគម្រប់សម្រាប់បាញ់ទឹកលាងឧបករណ៍ផ្សេងៗនិងសម្រាប់ផ្ទុកទឹកបិត។
របៀបប្រើប្រាស់: ជាទូទៅដបនេះសម្រាប់ដាក់ទឹកបិត ឬទឹកបន្ទូរអ៊ីយ៉ុង ឬទឹកស្អាតសម្រាប់បាញ់លាងជម្រះឧបករណ៍ពិសោធនៅវគ្គចុងក្រោយបន្ទាប់ពីលាងជាមួយទឹកសាប៊ូ និងទឹកម៉ាស៊ីនរួច។



## ត្បាល់ និងអង្រែ

ប្រភេទ៖ អាចមានជាប្រភេទកែវ និងប្រភេទព័រសឺឡែន និងមានទំហំតូចធំទៅតាមប្រភេទរបស់វា។
របៀបប្រើប្រាស់:  ប្រើសម្រាប់កិនកម្ទេចសារធាតុគីមីរឹងផ្សេងៗពីគ្រាប់ធំៗទៅគ្រាប់តូចៗ ឬកិនឱ្យម៉ត់។



## ក្រដាសតួណឺសុល

ប្រភេទ៖  ក្រដាសតួណឺសុលមានពីរប្រភេទ  គឺក្រដាសតួណឺសុលខៀវ និងក្រដាសតួណឺសុលក្រហម។
របៀបប្រើប្រាស់: ក្រដាសតួណឺសុលត្រូវបានគេប្រើដើម្បីធ្វើតេស្តលក្ខណៈអាស៊ីត-បាសនៃសូលុយស្យុង។




## ក្រដាស pH

ប្រភេទ៖ ក្រដាសpH មិនមានច្រើនប្រភេទទេ បើទោះជាខ្លះគេធ្វើវាជាក្រដាសតូចៗ ឬជាដុំរមូក៏ដោយក៏វានៅតែជាប្រភេទដូចគ្នាដដែល។
របៀបប្រើប្រាស់: ក្រដាស pH ត្រូវបានគេប្រើដូចក្រដាសតួណឺសុលដែរ តែវាមានលក្ខណៈប្រសើរជាង។ ដើម្បីវាស់ pH នៃសូលុយស្យុងគេយកក្រដាស pH ជ្រលក់ក្នុងសូលុយស្យុងនោះ រួចលើកមកវិញហើយទុកវាឱ្យស្ងួត ទើបយកវាទៅប្រៀបធៀបពណ៌ស្តង់ដារបស់វា និងអានតម្លៃ pH ទៅតាមនោះ។



## pHម៉ែត្រ

ប្រភេទ៖ pH ម៉ែត្រជាឧបករណ៍ឌីជីថលមានពីរប្រភេទគឺ pH ម៉ែត្រចល័ត និង pH ម៉ែត្រអចល័ត។ pH ម៉ែត្រចល័ត ជាប្រភេទតូចប្រើថ្មដែលគេអាចទុកដាក់តាមខ្លួន ឬអាចប្រើចល័តនៅក្រៅថ្នាក់បាន។ pH ម៉ែត្រអចល័ត ជាប្រភេទធំប្រើចរន្តអគ្គិសនី ជាទូទៅគេតែងតែដាក់វានៅលើតុមួយកន្លែង។ pH នេះបង្ហាញតម្លៃជាក់លាក់ និងសុក្រិតជាង pH ម៉ែត្រចល័ត។

របៀបប្រើប្រាស់: ទាំងប្រភេទ pH ម៉ែត្រចល័ត និងអចល័តមានរបៀបប្រើដូចគ្នា។ ខាងក្រោមនេះជាដំណើរការកំណត់ស្តង់ដារ pH ម៉ែត្រទូទៅមួយ។ ១. បើកកុងតាក់ភ្ជាប់ចរន្តអគ្គិសនី។ ២. លាងអេឡិចត្រូតរបស់ pH ម៉ែត្រជាមួយទឹកបិតឱ្យស្អាត រួចដាក់វាចូលទៅក្នុងសូលុយស្យុងតំប៉ុងស្តង់ដាដែលមានតម្លៃ pH=4.00, pH=7.00 ។ ៣. ដកអេ
ឡិចត្រូត pHម៉ែត្រចេញពីសូលុយស្យុងតំប៉ុងខាងលើ រួចបាញ់លាង
ដោយទឹកបិត និងជូតដោយក្រដាសជូតមាត់ឱ្យស្អាត។ ៤. pH ម៉ែត្រនេះអាចយកទៅប្រើដើម្បីវាស់តម្លៃ pH របស់សូលុយស្យុងភាគសំណាកផ្សេងៗបានហើយ។

**ប៊ុយរ៉ែត**

ប្រភេទ៖ ប៊ុយរ៉ែតអាចមានទំហំតូច ធំដូចជា 25mL ឬ 50mL និងផលិតអំពីកែវ។

របៀបប្រើប្រាស់: ប៊ុយរ៉ែតត្រូវបានគេប្រើប្រាស់សម្រាប់ធ្វើអត្រាកម្មរកកំហាប់នៃសូលុយស្យុងភាគសំណាកដែលមិនស្គាល់ដោយប្រើសូលុយស្យុងស្តង់ដាដែលស្គាល់កំហាប់ច្បាស់។

**កែវវាស់មាឌ**

ប្រភេទ៖កែវវាស់មាឌមានទំហំខុសៗគ្នាដូចជា25mL, 50mL, 100mL, 250mL, 500mL និង1000mL។ កែវវាស់មាឌមានក្រិតតែមួយទេដែលក្រិតនោះបង្ហាញពីចំណុះមាឌនៃកែវនោះតែម្តង។




របៀបប្រើប្រាស់: វាល់មាឌ ឬថ្លឹងម៉ាសភាគសំណាកដើមដែលត្រូវការចាំបាច់សម្រាប់ការពង្រាវដាក់ចូលទៅក្នុងកែវវាស់មាឌ។ ថែមទឹកបិតចូលប្រហែលកន្លះកែវវាស់មាឌរួចគ្រប និងគ្រឡុកឱ្យភាគសំណាករលាយអស់ក្នុងសូលុយស្យុង រួចបន្ថែមទឹកបិតរហូតដល់ក្រិត។



**ឡាវញែក**

ប្រភេទជាប្រភេទកែវមានឆ្នុក និងមានវាស់សម្រាប់បិតបើក និងបង្ហូរសូលុយស្យុង។



របៀបប្រើប្រាស់: គេប្រើឡាវញែកសម្រាប់ញែកសូលុយស្យុង ឬអង្គធាតុរាវពីរ ដែលមានផាសពីរផ្សេងគ្នា (មិនរលាយចូលគ្នា)។ បិទរ៉ើល និងចាក់សូលុយស្យុងល្បាយតាមមាត់ឡាវផ្នែកខាងលើ។ បិទឆ្នុកឱ្យជិត និងកាន់ឡាវទៅតាមលក្ខណៈបច្ចេកទេស។ ដៃមួយខ្ទប់ឆ្នុកឱ្យជាប់ និងដៃមួយទៀតកាន់ត្រង់រ៉ើលឡាវញែក។ គ្រលុក ២ ទៅ ៣ ដងរួចកាន់យកផ្នែករ៉ើលដាក់ទៅខាងលើ រួចមួលរ៉ើលបើកដើម្បីឱ្យឧស្ម័នចេញ។ បិទរ៉ើលវិញ និងធ្វើដូចដំណើរការទី៣រហូតដល់អស់ឧស្ម័នចេញនិងគិតថាការគ្រលុកបានសព្វល្អហើយ។ បិទរ៉ើល និងដាក់ល្បាយដែលគ្រលុករួចទុកវាឱ្យនឹងមួយកន្លែងនៅលើជើងទម្រដើម្បីទុកឱ្យសូលុយស្យុងញែកផាសពីរផ្សេងគ្នាបានល្អ។

**ចានសម្ងួត**

ប្រភេទ៖ ជាប្រភេទចានដែលធ្វើពីព័រសឺឡែន ស្តើងជាងចានចំហេះ និងមានទំហំខុសៗគ្នា។



របៀបប្រើប្រាស់: គេប្រើចានរំហួតសម្រាប់ធ្វើការរំហួតភាគសំណាក ទាំងអង្គធាតុរឹង និងអង្គធាតុរាវ ដោយកម្តៅ ឬដោយសម្រួល។

**ជើងទម្រ និងក្រចាប់**

ប្រភេទ៖ ភាគច្រើនជើងទម្រ និងឧបករណ៍ផ្សេងៗទៀតរបស់វាដូចជា ក្រចាប់ កងដែកជាដើមត្រូវបានគេធ្វើពីលោហៈ។ មានជើងទម្រខ្លះក៏គេធ្វើអំពីឈើផងដែរ។



របៀបប្រើប្រាស់: គេប្រើជើងទម្រសម្រាប់ចាប់ទ្រ ឬដំឡើងភ្ជាប់ជាមួយឧបករណ៍ផ្សេង ដូចជា ឧបករណ៍បំណិត ឡាវញែក ឬការដុតកម្តៅផ្សេងៗទៅតាមតម្រូវការ។

## ជញ្ជីងអេឡិចត្រូនិក




ប្រភេទ៖ ជញ្ជីងអេឡិចត្រូនិក ជាជញ្ជីងដើរដោយថាមពលអគ្គិសនី។ ជញ្ជីងខ្លះអាចប្រើថ្មពិលក៏បាន។ ជញ្ជីងនេះអាចមានសមត្ថភាពថ្លឹងបានសុក្រិតខ្លាំង រហូតដល់គេអាចទទួលបានតម្លៃលេខ៤ខ្ទង់ក្រោយក្បៀសទៅតាមប្រភេទដែលគេផលិត។

របៀបប្រើប្រាស់: របៀបប្រើប្រាស់ជញ្ជីងអេឡិចត្រូនិក

1. ចុចកុងតាក់ភ្ជាប់ចរន្តអគ្គិសនី។
2. ដាក់ក្រដាសទ្រាប់សារធាតុគីមី ឬឧបករណ៍ផ្សេងទៀតដូចជាកែវបេសឺ ឬកែវអ៊ែកឡែនជាដើម។
3. ចុចប៊ូតុងដែលមានសរសេរអក្សរថា«TARE» ឬ «Zero» ដើម្បីផាត់សំបក និងឱ្យជញ្ជីងបង្ហាញលេខសូន្យ។
4. ដាក់សារធាតុគីមីចូល ដើម្បីថ្លឹងនៅចំនួនដែលយើងត្រូវការ។
5. បិតកុងតាក់អគ្គិសនីវិញក្រោយប្រើប្រាស់រួច។

## ជញ្ជីងដងបី



ប្រភេទ៖ ជាប្រភេទជញ្ជីងបូលកូនដែលមានដងបី និងមានកូនទម្ងន់បីផ្សេងគ្នា។ ជញ្ជីងនេះមានសមត្ថភាពថ្លឹងចាប់ពី 0.01gរហូតដល់ 500g និងមានលក្ខណៈសុក្រិតដូចជាជញ្ជីងអេឡិចត្រូនិកដែរ។

របៀបប្រើប្រាស់:

1. រំកិលកូនទម្ងន់នៅលើដងជញ្ជីង
2. ទាំងបីមកដាក់ចំណុចសូន្យទាំងអស់
3. មួលតម្រូវប៊ូតុងសម្រាប់បូលកូនដើម្បីឱ្យចុងដងជញ្ជីងចង្អុលចំគំនូសលំនឹង
4. ដាក់វត្ថុលើថាសជញ្ជីង
5. ចាប់ផ្តើមរំកិលកូនទម្ងន់នៅលើដងកណ្តាលគេ (ធំជាងគេ) ឱ្យចំក្រិតនីមួយៗនៅលើដងជញ្ជីងរហូតដល់ដងជញ្ជីងធ្លាក់ចុះក្រោមគំនូសលំនឹងត្រូវរំកិលកូនជញ្ជីងមកក្រោមមួយក្រិតវិញ
6. ចាប់ផ្តើមរំកិលកូនទម្ងន់នៅលើដងជញ្ជីងខាងក្រោយគេ( ទំហំបន្ទាប់ )មួយក្រិតម្តងៗរហូតដល់ជញ្ជីងធ្លាក់ចុះក្រោមគំនូសលំនឹងត្រូវរំកិលកូនជញ្ជីងមកក្រោយមួយក្រិតវិញ
7. ចាប់ផ្តើមរំកិលកូនទម្ងន់នៅលើដងជញ្ជីងខាងមុខគេ (តូចជាងគេ) រហូតដល់ដងជញ្ជីងចង្អុលចំគំនូសលំនឹង
8. អានតម្លៃលេខសរុបនៃដងជញ្ជីងទាំងបី( មើលរូប ) ដែលតម្លៃនោះជាម៉ាសរបស់វត្ថុដែលថ្លឹង។

### ក្រូណូម៉ែត្រ



ប្រភេទ៖ ក្រូណូម៉ែត្រជាប្រភេទនាឡិកាឌីជីថលដែលអាចប្រើជានាឡិកាសម្រាប់មើលម៉ោង និងសម្រាប់វាស់ពេលវេលាផង។

របៀបប្រើប្រាស់: ក្រូណូម៉ែត្រត្រូវបានគេប្រើប្រាស់ជាទូទៅសម្រាប់វាស់រយៈពេលផ្សេងទាំងការសិក្សាវិទ្យាសាស្ត្រ និងផ្នែកកីឡា។ វាមានប៊ូតុងចំនួន៣គឺ៖ MOOD សម្រាប់ចុចផ្លាស់ប្តូរពីការបង្ហាញម៉ោងទៅជាក្រូណូម៉ែត្រសម្រាប់វាស់រយៈពេល។ START/STOP សម្រាប់ចុចពេលចាប់ផ្តើមវាស់រយៈពេលនិងចុចម្តងទៀតនៅពេលវាស់បានបញ្ចប់។ រយៈពេលដែលវាស់បាននោះនឹងបង្ហាញនៅលើចរ(អេក្រង់) របស់ក្រូណូម៉ែត្រ។ RESET សម្រាប់ចុចឱ្យលេខប្តូរទៅជា 0:00:00 វិញដើម្បីវាស់ រយៈពេលផ្សេងទៀត។

# ៦. ការសរសេរសន្លឹកកិច្ចការពិសោធន៍

## ៦.១.ប្រធានបទទី១ "ការកំណត់កំហាប់ភាគរយអាស៊ីតអេតាណូអ៊ិចក្នុងទឹកខ្មេះ"

### វត្ថុបំណង

- កំណត់កំហាប់ភាគរយអាស៊ីតអេតាណូអ៊ិចក្នុងទឹកខ្មេះដែលទិញពីផ្សារតាមវិធីអត្រាកម្មអាស៊ីត-បាស។
- រៀបចំដំឡើងសម្ភារៈដើម្បីធ្វើអត្រាកម្មអាស៊ីត-បាស
- មានបម្រុងប្រយ័ត្នពេលធ្វើពិសោធ

### ទ្រឹស្តី និងបញ្ញត្តិដែលពាក់ព័ន្ធ

ជាទូទៅទឹកខ្មេះដែលលក់នៅទីផ្សារមានបរិមាណអាស៊ីតអេតាណូអ៊ិច ($CH_3COOH$)ប្រហែល 3-5% គិតជាម៉ាស។ គោលបំណងនៃការពិសោធនេះ គឺដើម្បីកំណត់កំហាប់អាស៊ីតអេតាណូអ៊ិចពិតប្រាកដដែលមាននៅក្នុងទឹកខ្មេះដែលលក់នៅលើទីផ្សារ ដោយការធ្វើអត្រាកម្មជាមួយសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត ($NaOH$) អង្គធាតុចង្អុលពណ៌សមស្របត្រូវប្រើក្នុងអត្រាកម្មនេះ គឺផេណុលផ្តាលេអ៊ីន។ ផេណុលផ្តាលេអ៊ីនមានតំបន់ប្រែពណ៌របស់វាចន្លោះពី 8.2 ដល់ 10.0 និងពេលប៉ះជាមួយសូលុយស្យុងអាស៊ីតវាមិនបង្ហាញពណ៌ ហើយបើពេលប៉ះជាមួយសូលុយស្យុងបាសវិញវាឱ្យជាពណ៌ក្រហមស្វាយ។

សមីការតាងប្រតិកម្ម៖ $CH_3COOH + NaOH \rightarrow CH_3COONa + H_2O$

### ឧបករណ៍ និងសារធាតុគីមី

- ជើងទម្រ និងអង្កៀ
- កែវបេស៊ែចំណុះ 150 mL
- ប៊ុយរ៉ែត
- ពីប៉ែត
- ទឹកខ្មេះ
- សូលុយស្យុង NaOH ស្តង់ដាកំហាប់ 0.1 M
- កែវអ៊ែកឡែន
- ទឹកបិត
- ដបទឹកសម្រាប់លាង
- កែវវាស់មាឌចំណុះចំណុះ 250 mL
- អង្គធាតុចង្អុលពណ៌ផេណុលផ្តាលេអ៊ីន

- ជញ្ជីងអេឡិចត្រូនិក
- ស៊ីឡាំងក្រិត














## ដំណើរការពិសោធន៍

1. ដាក់ទឹកខ្មេះ 20 mL ទៅក្នុងកែវវាស់មាឌចំណុះ 250mL ដោយប្រើពីប៉ែត
2. បន្ថែមទឹកបិតរហូតដល់គំនូសក្រិត បិទគម្រប និងគ្រឡុកវាឱ្យសព្វ
3. លាងជម្រះពីប៉ែតជាមួយសូលុយស្យុងទឹកខ្មេះទើបទធ្វើបាននេះ
4. បូមយកសូលុយស្យុងទឹកខ្មេះ 20 mL ដាក់ទៅក្នុងកែវអែកឡែនដោយប្រើពីប៉ែត
5. បន្ថែមសូលុយស្យុងអង្គធាតុចង្អុលពណ៌ 2-3 តំណក់ទៅក្នុងកែវអែកឡែននោះ
6. បំពេញសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីតស្តង់ដារទៅក្នុងប៊ុយរ៉ែតដោយប្រើឡាវ
7. ធ្វើអត្រាកម្មអាស៊ីតទឹកខ្មេះដែលពង្រាវរួចដោយសូលុយស្យុងស៊ូត នឹងធ្វើតាមលំនាំដដែលឱ្យបានបីដង។
8. បូមយកសូលុយស្យុងទឹកខ្មេះ 10 mL ដាក់ចូលក្នុងស៊ីឡាំងក្រិត រួចថ្លឹងម៉ាសជាមួយជញ្ជីងដើម្បីកំណត់រកដង់ស៊ីតេ។

## ការសង្កេត និងលទ្ធផល

បំពេញលទ្ធផលក្នុងតារាងខាងក្រោមនេះ៖

| អំណានប៊ុយរ៉ែត | លើកទី១ | លើកទី២ | លើកទី២ |
|---|---|---|---|
| អំណានដើម | | | |
| អំណានបញ្ចប់ | | | |
| មាឌប្រើអស់ | | | |
| មាឌប្រើអស់មធ្យម | | | |

## ការវិភាគ និងសន្និដ្ឋាន

ក. គណនាកំហាប់ម៉ូឡារីតេរបស់អាស៊ីតអេតាណូអ៊ិចនៅក្នុងទឹកខ្មេះ។

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

..............................................................................................................................។

ខ. គណនាកំហាប់ម៉ូឡារីតេរបស់អាស៊ីតអេតាណូអ៊ិចនៅក្នុងទឹកខ្មេះដើម។

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

គ. គណនាកំហាប់ជាភាគរយរបស់អាស៊ីតអេតាណូអ៊ិចនៅក្នុងទឹកខ្មេះដើម។

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

## ៦.២.ប្រធានបទទី២ កត្តាជះឥទ្ធិពលលើល្បឿនប្រតិកម្ម

### វត្ថុបំណង

បកស្រាយពីឥទ្ធិពលទំហំភាគល្អិតរបស់អង្គធាតុប្រតិករទៅលើល្បឿនប្រតិកម្ម។

### ទ្រឹស្តី និងបញ្ញត្តិពាក់ព័ន្ធ

- ប្រតិកម្មគីមីជាការប៉ះទង្គិចរវាងភាគល្អិតពីរ ឬច្រើន ដែលនាំឱ្យមានការបែកបាក់សម្ព័ន្ធគីមីចាស់ និងបង្កើតសម្ព័ន្ធគីមីថ្មី ឬ ជាការបម្លែងពីអង្គធាតុមួយ ទៅជាអង្គធាតុមួយថ្មីទៀត។
- ការប៉ះទង្គិចណាដែលកម្លាំងទង្គិចមិនគ្រប់គ្រាន់ មិនបណ្តាលឱ្យមានប្រតិកម្មកើតឡើង ការប៉ះទង្គិចនេះហៅថា មិនបានការ។
- ការប៉ះទង្គិចណាដែលកម្លាំងទង្គិចខ្លាំងគ្រប់គ្រាន់ បណ្តាលឱ្យមានប្រតិកម្មកើតឡើង ការប៉ះទង្គិចនេះហៅថា ទង្គិចប្រសិទ្ធ។

- ប្រតិកម្មគីមីមួយ ប្រព្រឹត្តិទៅកាន់តែលឿន ពេលមានចំនួនទង្គិចប្រសិទ្ធ កាន់តែច្រើន។ ដើម្បីបង្កើនចំនួនទង្គិចប្រសិទ្ធ យើងអាចៈ

  ១. បង្កើនផ្ទៃប៉ះ(កត្តាទំហំភាគល្អិត)
  ២. បង្កើនកំហាប់សូលុយស្យុង (កត្តាកំហាប់)
  ៣. បង្កើនសម្ពាធ(កត្តាសម្ពាធ)
  ៤. បង្កើនសីតុណ្ហភាព(កត្តាសីតុណ្ហភាព)
  ៥. ប្រើកាតាលីករ(កត្តាកាតាលីករ)

  ខាងក្រោមវណាយើងនឹងអនុវត្តពិសោធតាមវិធីរិះរក ទៅលើកត្តាទំហំភាគល្អិត។

## សន្លឹកកិច្ចការពិសោធន៍ទី២

«ឥទ្ធិពលទំហំភាគល្អិតអង្គធាតុប្រតិករ លើល្បឿនប្រតិកម្ម»

.........................................................................

សង្កេតៈ គេមានដុំសាប៊ូ A មួយរាងគូប មានជ្រុងប្រវែង 1cm។




ក. ចូរគណនាផ្ទៃមុខសរុបរបស់គូប។

.........................................................................

.........................................................................

.........................................................................

.........................................................................

.........................................................................

ខ. ប្រសិនបើគេកាត់សាប៊ូជាពីរចំណែកស្មើគ្នា គេបានដុំសាប៊ូ $A_1$ និង$A_2$។

.........................................................................

.........................................................................

.........................................................................

.........................................................................

.........................................................................

គ. ទាក់ទងនឹងប្រតិកម្មគីមី បើគេយកអង្គធាតុ A ឱ្យមានប្រតិកម្មជាមួយសុលុយស្យុង S និងមួយទៀតគេយកអង្គធាតុ A1+A2 ឱ្យមានប្រតិកម្មជាមួយសូលុយស្យុង S ដែរ តើល្បឿនប្រតិកម្មប្រព្រឹត្តទៅដូចគ្នាដែរឬទេ?

១. សំណួរគន្លឹះ« តើក្នុងករណីម៉ាសស្មើគ្នា អង្គធាតុប្រតិករមានទំហំភាគល្អិតខុសគ្នា មានឥទ្ធិពលទៅលើល្បឿនប្រតិកម្មយ៉ាងដូចម្តេច?»

២. ការបង្កើតសម្មតិកម្ម( ចូរសាកល្បងឆ្លើយសំណួរគន្លឹះខាងលើ)

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៣. ផែនការពិសោធ (ដើម្បីបញ្ជាក់ថាប្រតិកម្ម ឬចម្លើយសាកល្បង ដែលបានបង្កើត ត្រូវឬខុស តើយើងគួរធ្វើពិសោធបែបណាដើម្បីរកការពិត)

ប្រើសម្ភារៈ( ឧបករណ៍ និងសារធាតុគីមី)

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

ដំណើរការ

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៤. ការសង្កេត និងលទ្ធផល

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

.......................................................................................................................................

.......................................................................................................................................

៥. សំណួរពិភាក្សា និងសេចក្ដីសន្និដ្ឋាន

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

## ៧.វិធីសាស្រ្តបង្រៀន និងរៀនពិសោធន៍

សម្រាប់ការបង្ហាញពិសោធន៍ដោយគ្រូបង្គោលទៅលើប្រធានបទទាំងពីរខាងលើនេះ ប្រធានបទទី១ គឺប្រើប្រាស់ វិធីបង្រៀន និងរៀន តាមវិធីវិទ្យាសាស្ត្រដែលមានជំហានសំខាន់ៗដូចតទៅ: ១. ការកំណត់បញ្ហា ២. ការបង្កើតសម្មតិកម្ម ៣. ការធ្វើតេស្តសម្មតិកម្ម (ការធ្វើពិសោធ) ៤. លទ្ធផល ៥. ការវិភាគ និងសន្និដ្ឋាន

ចំពោះប្រធានបទទី២វិញ គឺប្រើប្រាស់វិធីបង្រៀន និងរៀនតាមបែបរិះរកដែលមានជំហានសំខាន់ៗដូចតទៅ: ១. ការបង្ហាញបាតុភូត ២. ការបង្កើតសំណួរគន្លឹះ ៣. ការបង្កើតសម្មតិកម្ម ៤. ការធ្វើតេស្តសម្មតិកម្ម (ការធ្វើពិសោធន៍) ៥. លទ្ធផល និងពិភាក្សា ៦. ការធ្វើសេចក្ដីសន្និដ្ឋាន។

## ៨.សារប្រយោជន៍នៃសម្ភារៈឧបទេស

សម្ភារឧបទេសគឺជាអ្នកដឹកនាំពីគ្រូទៅឱ្យសិស្សក្នុងថ្នាក់។ ដូច្នេះគ្រូបង្រៀនអាចសម្រេចវត្ថុបំណងមេរៀនបានយ៉ាងមានប្រសិទ្ធភាពតាមរយៈការប្រើប្រាស់សម្ភារឧបទេសដែលសមស្រប។

សម្ភារឧបទេសមានតួនាទី:

- ធ្វើឱ្យការបង្រៀនប្រព្រឹត្តទៅបានល្អ បង្កើតរូបារម្មណ៍ បង្កើតគំនិតថ្មីងាយស្រួលក្នុងការបង្រៀន និងរៀន
- ផ្សារភ្ជាប់ទ្រឹស្ដីទៅនឹងការអនុវត្ត
- ធ្វើអ្វីដែលអរូបីឱ្យមានលក្ខណៈរូបី
- ពង្រឹងចំណេះដឹងបណ្ដុះស្មារតីសិស្ស
- ធ្វើឱ្យសម្រេចវត្ថុបំណងមេរៀន

- ធ្វើឱ្យថ្នាក់រៀនមានលក្ខណៈសកម្ម និងមានភាពរស់រវើកដោយសិស្សបានសង្កេតជាក់ស្តែងរិភាគសំយោគដោយខ្លួនឯង
- វាជាវិធីធ្វើឱ្យសិស្សចងចាំបានយូរ និងមានចំណូលចិត្តក្នុងការសិក្សា
- ដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែច្បាស់លាស់និងងាយយល់

# ៩. ឯកសារយោង


1. វិទ្យាស្ថានជាតិអប់រំ សៀវភៅវិធីសាស្ត្របង្រៀនសម្រាប់ការបណ្តុះបណ្តាល បោះពុម្ពឆ្នាំ២០១៩
2. ក្រសួងអប់រំ យុវជន និងកីឡា សៀវភៅសិក្សាគោលគីមីវិទ្យាថ្នាក់ទី១២ បោះពុម្ពឆ្នាំ២០១៩
3. វិទ្យាស្ថានជាតិអប់រំ សៀវភៅណែនាំពីការប្រើប្រាស់សម្ភារៈពិសោធន៍ បោះពុម្ពឆ្នាំ២០០៥